ភ្នំពេញ , ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣

# អនុក្រឹត្យលេខ ០៤ អ.ន.ក្រ
# ស្តីពីឯកសណ្ឋាន និង ផ្លាកសញ្ញាកងទ័ពជាតិកម្ពុជា

* * * *

## សហប្រធាននៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

* * * *

- យោងតាមក្រឹត្យ ចុះថ្ងៃទី ០២ ខែ កក្កដាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាល ជាតិបណ្តោះអាសន្ននៃកម្ពុជា
- យោងតាមក្រឹត្យ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីសញ្ញាឋានន្តរស័ក្តិកងទ័ពជាតិកម្ពុជា
- យោងតាមក្រឹត្យស្តីពីរូបភាព និង ខ្នាតលំដាប់ស័ក្តិកងទ័ពជាតិ
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គសេនាធិការកងទ័ពជាតិកម្ពុជា

## សំរេច

**មាត្រា ១ :** - ត្រូវបានរៀបចំឯកសណ្ឋានកងទ័ពជាតិប្រភេទទ័ពជើងគោកដូចខាងក្រោម :

រូបភាព និង ខ្នាតឯកសណ្ឋាន :

ក- ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ រួមមាន ៧ សំរាប់គឺ :

១- ឯកសណ្ឋានធំលេខ ១ " កុដស "

អាវកុដសកត្រង់ ខោវែងខៀវចាស់ក្រហម ពីរ មួកធំពណ៌ខ្មៅសំរាប់ពាក់ក្នុងពិធីបុណ្យជាតិធំៗ និងពិធីក្នុងព្រះបរមរាជវាំង ។

រូបភាព និង ខ្នាត :

អាវកុដសកត្រង់កាត់រាងអាវធំ គ្មានតែគខ្ទង់ កអាវមានប៉ាក់ ដូចធ្មេញរណារ ពណ៌មាសជុំវិញលើស្មាមាន ប៊ូល ហោប៉ៅ ៤ ' ពីខាងលើដេរប៉ះ ចំកណ្តាលមានចាប់ផ្នត់មួយ គំរបរាងស្លឹកពោធិពីខាងក្រោម ដេរចង្កូមមាន គំរបរាងចតុកោណកែង " អាវដៃវែង លើផ្លេរចុងដៃអាវមានប៉ានក្រណាត់ពណ៌ មាសទំហំ ៨ ម.ម ឡេវមានរូប ព្រះសង្ហារពណ៌មាសចំនួន ៧ នៅចុងដៃអាវមានឡេវបញ្ចោត បី ។

- ខោជើងវែងចង្អេះត គ្មានគ្លី នៅខាងក្រោយមានហោប៉ៅមួយ ដេរចង្កូមគ្មានគំរប ហោប៉ៅ ពីរ ដេរចង្កូម នៅចំហៀងតាមថ្នេរខោ មានប៉ានក្រហមពីរ ប៉ាននិមួយៗ មានទទឹង ២ ស.ម ។

- មួក កាស្កេត ខាងលើក្រណាត់ កាំទ្រី ពណ៌ក្រម៉ៅ ជើងមួកនិងហាមពណ៌ខ្មៅ រ័ន្ត និងឡេវរូបព្រះសង្ហាពណ៌មាស នៅលើហាមមួកមានប៉ាក់ក្បាច់ភ្ញី ទេសឌិន ដល់ជើងមួក ពណ៌មាស ។

- ខ្សែឥស្សរយសពណ៌មាសវេញចូលគ្នាបីខ្សែអមចី មានបន្ទោកម្ជុលពីរពណ៌មាសពាក់លើស្មាស្តាំ ។

- ស្បែកជើងស្បែកកខ្លី ពណ៌ខ្មៅ ចងខ្សែ ស្រោមជើងខ្មៅ ស្រោមដៃស ។

**២ - ឯកសណ្ឋានធំលេខ ២ :**

សំរាប់ពាក់ក្នុងពេលធ្វើមិទ្ទិញ បំពេញបេសកកម្មនៅក្រៅប្រទេស ទទួលភ្ញៀវជាតិ អន្តរជាតិ អាវខោនិងមួក ក្រណាត់តេហ្គាល់ ពណ៌តតីរ ។

**- រូបភាព និង ពណ៌ :**

- អាវកាត់រាងអាវ វ៉ារីមានផែកខ្នង គបើក ប៉ូលស្មា មានហោប៉ៅបួន ដេរប៉ះ " ហោប៉ៅពីរ លើ ដេរបត់ផ្នត់កណ្តាល គំរបរាងស្លឹកពោធិពីរ ខាងក្រោម គំរបរាងចតុកោណកែង " ឡេវ ៤ មានរូបព្រះសង្ហាពណ៌មាស អាវដៃវែង ចុងដៃអាវមានដាក់ឡេវបញ្ឆោតបី " ។

- ខោជើងវែងផ្នេរបង្កប់ ចង្កេះគគ្មានក្លី មានហោប៉ៅបួន " ខាងក្រោយពីរដេរបង្កប់ គំរបរាងស្លឹកពោធិ នៅចំហៀងពីរ ដេរបង្កប់តាមផ្នេរខោ "។

- មួកកាស្កេត ក្រណាត់តេហ្គាល់ពណ៌តតីរ ជើង និង ភោមមួកពណ៌ខ្មៅ វ័ន្តមួក និង ឡេវ មានរូបព្រះសង្ហា ពណ៌មាស លើបាមមួកមានជាក់ក្បាច់ភ្ញីទេសខិនពណ៌មាសដល់ជើងមួក ។

- អាវសឺមី ក្នុងកខុប ក្រណាត់តេតារ៉ុង ពណ៌ស ពាក់នៅពេលរាត្រី នៅពេលថ្ងៃ ពណ៌តតីរ អាវដៃវែង មានហោប៉ៅមួយ គ្មានគំរប កាត់ស្រុងវែង ដាក់ក្នុងខោ ។

- ក្រវ៉ាត់កពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

- ស្បែកជើងស្បែកពណ៌ខ្មៅ កខ្លី ចងខ្សែ ស្រោមជើងពណ៌ខ្មៅ ។

- ខ្សែក្រវ៉ាត់ពណ៌តតីរ ក្បាលខ្សែក្រវ៉ាត់ពណ៌មាសភោគ ។

- ខ្សែឥស្សរយសពណ៌មាស " ដូចខាងលើ " ។

* ចំពោះយុទ្ធនារី អាវដូចគ្នាខាងលើ តែជីពចង្កេះ និង កអាវរាងនារី សំពត់ហ្សីបក្រោមជង្គង់ ។

**៣- ឯកសណ្ឋានលេខ ៣ "សាយោធិន" :**

- សំរាប់ពាក់ក្នុងពិធីការ ដូចជាបើកបិទវគ្គរៀនសូត្រ ពិធីសមោសរ និង ជប់លៀង ។ ល។ អាវនិងមួកក្រណាត់ តេហ្គាលពណ៌តតីរ ខោក្រណាត់តេហ្គាលពណ៌ត្រេអ៊ី ។

**រូបភាព និង ពណ៌ :**

- អាវដៃខ្លីកបើក ហោប៉ៅបួន " ពីខាងលើដេរប៉ះគំរបរាងចតុកោណកែង ពីខាងក្រោមដេរបោតមកក្រៅ មានគំរបរាងចតុកោណកែង " ប៉ាស្មា ខ្នងជីពក្លី ២ គ្មានផែកឡេវធម្មតាពណ៌តតីរ នៅចង្កេះមានក្រវ៉ាត់ជាប់អាវទំហំ ៦ ស.ម ក្បា[illegible] ក្រវ៉ាត់រាងពងក្រពើ មានរូបម្កុដ ព្រះខ័នមានពានទ្រ ។

- ខោជើងវែងក្រណាត់តេហ្គាលព[illegible] " ម៉ូតដូចឯកសណ្ឋានធំលេខ ២ " ។

- មួកស្បែកជើង និង ស្រោមជើង " ដូចឯកសណ្ឋានលេខ ២ " ។

* ចំពោះនារីអាវកបើក ជីពចង្កេះតាមរាងនារី សំពត់ហ្ស៊ីបក្រោមជង្គង់ ។

**៤ ឯកសណ្ឋានការងារដៃខ្លីពណ៌តេតឺរ :**

សំរាប់ពាក់ធ្វើការក្នុងការិយាល័យ ក្នុងបន្ទាយ និង ទាក់ទងស្ថាប័ននានាក្នុងប្រទេស ។

**- រូបភាព និង ខ្លឹម :**

- អាវដៃខ្លីត្រូវកាត់តេហ្គាលពណ៌តេតឺរកខុប ប៉ូលីស្ទា កាត់ស្រួងវែងដាក់ក្នុងខោ ហោប៉ៅ ពីរ ដេ
ប៉ះចំកណ្តាល ដេរបត់ផ្នត់មួយមានគំរបរាងស្លឹកពោធិ ឡេវធម្មតាពណ៌តេតឺរ ។

- ខោ និង មួកកាស្កេតពណ៌ក្រណាត់ និង ម៉ូតដូច មួក និងថ្ពេរមានចំពាក់ទីតមាសពាក់បញ្ចេញខាងស្តាំ ។

* ចំពោះនារីអាវដូចបុរស សំពត់ហ្ស៊ីបក្រោមជង្គង់ ឬ ខោឡេវចំហៀង ។

**៥ - ឯកសណ្ឋានការងារអាវដៃខ្លីពណ៌ត្រែអ៊ី :**

ក្រណាត់តេហ្គាលពណ៌ត្រែអ៊ី ដូចឯកសណ្ឋានការងារដៃខ្លីខាងលើ តែខុសពណ៌ត្រែអ៊ី អាវកបើ
និង ក្រវ៉ាត់ ចង្កេះទីហំ ៥ ស.ម ។

**៦ - ឯកសណ្ឋានការងារដៃវែងពណ៌តេតឺរ :**

សំរាប់ពាក់ដូចឯកសណ្ឋានការងារដូចខាងលើ ។

**- រូបភាព និង ខ្លឹម :**

- អាវដៃវែងកខុប ប៉ូលីស្ទា ហោប៉ៅពីរ " ដូចខាងលើ " អាវដៃវែងកាត់ស្រួង វែងដាក់ក្នុងខោ

- ខោ មួក ស្បែកជើងដូចឯកសណ្ឋានការងារ អាវដៃខ្លីពណ៌តេតឺរ ។

**៧ - ឯកសណ្ឋានប្រយុទ្ធ :**

សំរាប់ពាក់ពេលប្រតិបត្តិការ ហ្វឹកហាត់ និង ចុះបេសកកម្ម ។ ឯកសណ្ឋានពណ៌ត្រែអ៊ី " ទ័
ពិសេស និង ទ័ពទន្ត្រៃយោងពណ៌ជាំ " រួមមាន ២ សំរាប់ ៈ មួយសំរាប់អាវហោប៉ៅបួ
មួយសំរាប់ទៀត អាវហោប៉ៅពីរ " ។

**- រូបភាព និង ខ្លឹម :**

- អាវដៃវែងកបើក ថ្ពេរខុប ប៉ូលីស្ទា ហោប៉ៅបួនដេរយោគ មានគំរបរាងចតុកោណកែង ដេ
ចង្កប់នៅចុងដៃអាវ រង្វង់កដៃបំពាក់មានឡេវក្រវ៉ាត់ ខ្សែក្រវ៉ាត់ធំ " សាំងទ្យ៉ុង " ក្រវ៉
នៅចង្កេះពី លើអាវ ។

- អាវដៃខ្លីកបើក ថ្ពេរខុប ប៉ូលីស្ទា ហោប៉ៅពីរដេរយោគ មានផ្នែកកណ្តាល គំរបរាង ចតុកោណ
កែង ដេរស្រួងដាក់ក្នុងខោ ឡេវបង្កប់ ។

៤ - កងកិត្តិយសប្រើដាវ ពាក់ឯកសណ្ឋានធំលេខ ១ ថ្នាក់អនុសេនីយ៍ប្រើដាវមានស្រោមពណ៌ស ខ្សែរំយោល ដាវពណ៌មាស ដងដាវឆ្លាក់រូបព្រហ្ម ផ្លែដាវពណ៌ទឹកប្រាក់ ចង្កឹ និង ដងដាវក្បាច់ពណ៌មាស ។

មាត្រា ៤ : - ត្រូវបានរៀបចំផ្លាកសញ្ញាកងទ័ពជាតិដូចខាងក្រោម ÷

ក - រូបព្រះសង្ហា :

រូបព្រះសង្ហាយកតាមសម័យសង្គមរាស្ត្រនិយម ធ្វើពីលោហធាតុពណ៌មាស សំរាប់ពាក់លើមួកកាស្កេត និង ស៊ូកាស ទំហំកំពស់ ៧,៥ ស.ម ទទឹង ៦ , ៥ ស.ម ។ សំរាប់ពាក់លើមួកហ្សកពីបោនេ មួកហ្វាមធំ និង បេរ៉េ កំពស់ ៥ ស.ម ទទឹង ៤ ស.ម ។

ខ - ផ្លាកសញ្ញាកងទ័ពជាតិ : មានពីរប្រភេទគឺ ÷

១ - ផ្លាកសញ្ញាពាក់លើដៃអាវស្តាំ ចុះពីលើថ្នេរសា ៥ ស.ម មានរាងមូលបន្ទាត់ផ្ចិត ៨ ស.ម ស្រទាប់ខាងក្រៅពណ៌ស ទំហំ ៣ ម.ម នៅខាងលើ ១/៤ ពណ៌ខៀវសរសេរអក្សរ « កម្ពុជា » កំពស់អក្សរ ៧ ម.ម នៅខាងក្រោម ១/៤ ពណ៌ខៀវសរសេរអក្សរពណ៌ស « កងទ័ពជាតិ » កំពស់អក្សរ ៦ ម.ម នៅចំកណ្តាល ១/២ នៃផ្ទៃពណ៌ ក្រហម កណ្តាលមានប្រាសាទអង្គរវត្ត កំពូល ៣ ពណ៌ស កំពស់ប្រាសាទកណ្តាល ២,៥ ស.ម បាត ៤ ស.ម ។

២ - ផ្លាកសញ្ញារូបហនុមាន ធ្វើរាងជាមេដៃពាក់បន្តោងនៅខ្សែរហោជៅអាវខាងស្តាំ ធ្វើរាងមូលពីព័រស៊ីឡែន មានបន្ទាត់ផ្ចិត ៣ , ៥ ស.ម ផ្ទៃបែតងហនុមានកាន់ព្រះខ័នពណ៌មាស មានស្បែកសំរាប់បន្តោងប្រវែង ៨ ស.ម ខាងក្រោមសរសេរអក្សរកាត់ « ក.ឌ.ជ.ក » ។

គ - ផ្លាកឈ្មោះ មានពីរប្រភេទ :

១ - ផ្លាកជ័រញ្ជាស្ទិច ពណ៌បៃតង គូសបន្ទាត់ជុំវិញ និង អក្សរពណ៌លឿងបណ្តោយ ១០ ស.ម ទទឹង ២ ស.ម កំពស់អក្សរ ១០ ម.ម សរសេរអក្សរខ្មែរមួយ និង អក្សរឡាតាំងមួយ នៅខាងដើមឈ្មោះ សរសេរកាត់ពីឋានន្តរសក្តិរបស់នាយទាហាន នាយទាហានរង និងពលទាហាន : ឧត្តមសេនីយ៍អក្សរកាត់ " ឧ " វរសេនីយ៍ " វ " អនុសេនីយ៍ " អ " នាយទាហានរង និងពលទាហាន " ព " កំពស់អក្សរ ៧ ម.ម សំរាប់ពាក់លើឯកសណ្ឋានធំ និង ឯកសណ្ឋានការងារ ពាក់លើហោប៉ៅអាវខាងស្តាំ ។

២ - ផ្លាកឈ្មោះធ្វើក្រណាត់ ពណ៌ត្រែអ៊ី ដេរភ្ជាប់អាវ បណ្តោយស្មើមាត់ហោប៉ៅ ទទឹង ២ ស.ម សរសេរអក្សរពណ៌ខ្មៅ សំរាប់ដាក់លើឯកសណ្ឋានប្រយុទ្ធ កំពស់អក្សរ និង កន្លែងពាក់ដូចផ្លាកខាងលើ ។

មាត្រា ៥ : ចំពោះឯកសណ្ឋានកងអាវុធហត្ថជាតិកម្ពុជា ទ័ពជំនាញ និង សញ្ញាសំគាល់ ប្រភេទទ័ពមានការកំណត់ដោយឡែក ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីការពារជាតិ និង នាយអគ្គសេនាធិការកង ទ័ពជាតិត្រូវអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៧ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា និង ត្រា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * * *